# ជំងឺដុំខ្មៅក្នុងសាច់ត្រី

## ១-មូលហេតុបង្កជំងឺ

មេរោគបង្កជំងឺ គឺ ព្រូននីអូដីផ្លូសស្តូមមូមអូទីកូលា & Neaseuseuticola & Tetracotyle euticola ។ វាស្ថិតនៅក្នុងអំបូរជាមួយគ្នាជាមួយព្រូន Diplostomum ។ Neodiplostomum មានប្រវែង 0,៥ - ២មម ចែកចេញជាពីរផ្នែកគឺ

. ផ្នែកក្បាល មានរង្វង់មាត់សំរាប់ជញ្ជក់ រហូតដល់បំពង់អាហារ

. ផ្នែកខ្លួន មានពោះវៀនដែលបែកជាខ្នែងពីរ និងមានរង្វង់ពោះសំរាប់តោង ។

- ខួបជីវិតរបស់ព្រូន Neodiplostomum

ព្រូនពេញវ័យរស់នៅក្នុងពោះវៀនសត្វស្លាប សត្វស្លាបស៊ីត្រី ។ បន្ទាប់មកវាទំលាក់ពងតាមអាចម៍របស់សត្វស្លាបទៅក្នុងទឹក ។ ពងព្រូនញាស់ក្នុងទឹកក្លាយជាកូនញាស់ Meracidium រាងមូលពងក្រពើមានរោមជាច្រើន Meracidium ហែលសេរីក្នុងទឹករួចទន្រ្ទានចូលក្នុងខ្យង Limnaeastagnalis ពេលនោះវាបាតអស់រោម និងរីកលូតលាស់ក្លាយជា Sporoeyta បន្ទាប់មកក្លាយជា Redia ចូលទៅក្នុងថ្លើមខ្យងក្លាយជា Cercaria ។ Cercaria ចេញពីខ្យងហែលសេរីក្នុងទឹកជួបនិងត្រីវាទន្រ្ទានចូលក្នុងសាច់ត្រីតាមស្បែក និងស្រកី ។ Cercaria រស់នៅក្នុងសាច់ដុំត្រីក្លាយទៅជា Metacercaria ដែលមានភ្នាសពន្ធ័ជុំវិញ ។ សត្វស្លាបស៊ីត្រីដែលមានកូនព្រូន Metacercaria ចូលទៅក្នុងប្រពន្ធ័រំលាយអាហារពេលនោះក្រពេញរំលាយអាហារ សត្វស្លាបធ្វើអោយរំលាយភ្នាសពន្ធ័ជុំវិញ កូនព្រូនវាលូតលាស់ក្លាយជាព្រូនពេញរូបរាង នៅក្នុងពោះវៀនសត្វស្លាប ហើយបន្តខួបជីវិតដូចដើមឡើងវិញ ។




## ២-លក្ខណៈនៃជំងឺ

កូនព្រូន Neodiplostomum រស់នៅក្នុងសាច់ដុំត្រីរស់ ត្រីអណ្តែង ដោយមានភ្នាស់យ៉ាងក្រាស់ពណ៌ខ្មៅពទ្ធ័ជុំវិញ ។ ពេលត្រីមានជំងឺនេះគេហៅថា ជម្ងឺដុំខ្មៅសាច់ត្រី មិកសាច់ត្រី ។ ត្រីឈឺធ្វើសកម្មភាពតិច ហែលយឺតលើផ្ទៃទឹកដែលងាយស្រួលធ្វើជាចំណីដល់សត្វស្លាប ។ ត្រីមានជំងឺលូតលាស់យឺត ស្គមជួនកាលមានទំរង់រូបរាងមិនប្រក្រតី ។

## ៣-វិធីបង្ការោគ

នៅក្នុងបឹង អាងទឹកធម្មជាតិមានការលំបាកខ្លាំងនៅក្នុងស្រះចិញ្ចឹមត្រី ត្រូវបំបាត់ចោលពពួកខ្យង និងដេញបាញ់សត្វស្លាបដែលជាភ្នាក់ងារចំលងជំងឺ ។

# កត្តាមួយចំនួនដែលបណ្តាលអោយត្រីឈឺ

ទឹកជាមជ្ឈដ្ឋានរស់នៅរបស់ត្រី។ ត្រីរស់នៅធំធាត់បានដោយសារមជ្ឈដ្ឋានរស់នៅល្អពេលដែលមជ្ឈដ្ឋានរស់នៅមានការប្រែប្រួល ប្រភេទត្រីណាដែលមិនសំរបសំរួលជាមួយមជ្ឈដ្ឋានដែលប្រែប្រួលនោះ ងាយនឹងរងនូវជំងឺ ។

ត្រីដែលឈឺទទួលនូវឥទ្ធិពលអំពីកត្តាពីរយ៉ាងគឺ កត្តាខាងក្នុង និងកត្តាខាងក្រៅខ្លួនត្រី ។

## I - កត្តាខាងក្រៅ

### ១-កត្តាធម្មជាតិ

**ក-សីតុណ្ហភាពទឹក** ពេលសីតុណ្ហភាពទឹកប្រែប្រួលរហ័ស និងប្រថុចប្រថែចពេកបណ្តាលអោយត្រីឈឺ។ ចំពោះកូនត្រីម្សៅក្នុងអាងភ្ញាស់ ការប្រែប្រួលសីតុណ្ហភាពមិនត្រូវលើសពី ២ អង្សាសេ ។ ពេលផ្ទេរកូនត្រីពូជពីស្រះមួយទៅស្រះមួយសីតុណ្ហភាពទឹកមិនត្រូវខុសគ្នាលើសពី ៤ អង្សាសេឡើយ ។ សីតុណ្ហភាពទឹកប្រែប្រួលធំពេកអាចបណ្តាលឱ្យកូនត្រីស្លាប់ទាំងហ្វូង ។

**ខ-កំរិត $P^H$** $P^H$សមស្របសំរាប់ត្រីចិញ្ចឹមក្នុងស្រះពី ៧-៨,៥ ពេល $P^H$ តូចជាង ៥ ឬ ធំជាង ៩,៥ និងបណ្តាលអោយត្រីស្លាប់ ។

**គ-$O_2$ រលាយក្នុងទឹក** បរិមាណ $O_2$ រលាយក្នុងទឹកសមស្របសំរាប់ត្រីចិញ្ចឹមពី ៣-៥ Mg /L ទឹកពេល$O_2$ រលាយក្នុងទឹកមាន 1 Mg /L ទឹក ត្រីនឹងបើបក្បាលមកស្រូបយក $O_2$ ពីក្នុងបរិយាកាសហើយ ក្នុងរយះពេលខ្លីប្រសិនបើកំរិត$O_2$ រលាយក្នុងទឹកមិនកើនឡើងទេនោះត្រីស្ទះដង្ហើមងាប់ ។

**ឃ-សមាសភាពគីមី និងសារធាតុពុលក្នុងទឹក** នៅក្នុងស្រះចិញ្ចឹមត្រីខ្លះ មានសារធាតុសំណ សង្កសី បារ៉ត និងដែកមានក្នុងដីជាមួយបរិមាណដ៏ច្រើនបណ្តាលអោយត្រីមានជំងឺ ។ ការរីកចំរើននៃឧស្សាហកម្មប្រភពទឹកដែលទទួលឥទ្ធិពលនៃការបង្ហូរកាកសំណល់នៃរោងចក្រធ្វើអោយទឹកមានជាតិពុលបណ្តាលអោយត្រីឈឺ

### ២-កត្តាមនុស្ស

**ក- ដង់ស៊ីតេដាក់ត្រីចិញ្ចឹម** ដង់ស៊ីតេត្រីចិញ្ចឹមក្នុងស្រះពី ៣-៥ ក្បាល/ម$^2$ ផ្ទៃទឹក។ ប្រសិនបើដង់ស៊ីតេដាក់ត្រីខ្ពស់ពេកបណ្តាលអោយត្រីខ្វះ $O_2$ និងខ្វះចំណីដែលអាចបណ្តាលអោយត្រីឈឺ ។

**ខ- ការគ្រប់គ្រងស្រះចិញ្ចឹមត្រី** ការគ្រប់គ្រង និងអោយចំណីតាមបច្ចេកទេសចិញ្ចឹមធ្វើអោយត្រីមានសុខភាពល្អ មានការលូតលាស់ធំធាត់បានល្អ ផ្ទុយទៅវិញប្រសិនបើការចិញ្ចឹមពុំបានត្រឹមត្រូវតាមបច្ចេកទេសដូចជាអោយចំណីអាហារគ្មានអនាម័យ មិនធ្វើអនាម័យស្រះជាដើម បណ្តាលអោយស្រះកខ្វក់មានមេរោគធ្វើអោយត្រីឈឺ ។

**គ-ធ្វើអោយត្រីមានរបួស** ពេលកៀរអួន ឬសំណាញ់ចាប់ត្រីធ្វើអោយត្រីមានរបួសរលាត់ ក្នុងពេលដឹកជញ្ជូន ឬ ផ្ទេរទៅស្រះផ្សេងបណ្តាលអោយត្រីងាយរងនូវការជ្រៀតចូលរបស់មីក្រុប។

**៣-កត្តាសត្វ** ជម្ងឺត្រីភាគច្រើនបណ្តាលមកពីពពួកមីក្រុប ប៉ារ៉ាស៊ីតជាដើមបង្កជាជម្ងឺដល់ត្រី ។ ក្រៅពីនោះមានពពួកសត្វដែលស៊ីត្រី និងពពួកសត្វដែលធ្វើអោយត្រីមានគ្រោះថ្នាក់ ឬ សត្វស្លាបទឹក ពស់ត្រី សត្វល្អិតក្នុងទឹក។ល។

**ក-កត្តាខាងក្នុងខ្លួនត្រី** ត្រីមានភាពទប់ទល់នឹងមេរោគ និង រួចផុតពីឆ្លងមេរោគ ខុសគ្នាទៅតាមប្រភេទ និងអាយុរបស់វា ។

**ខ-**ក្នុងការចិញ្ចឹមត្រីចំរុះជាមួយគ្នាក្នុងស្រះតែមួយពេលដែលត្រីកាបស៊ីស្មៅមានជម្ងឺរលាកពោះវៀន ពេលនោះត្រីកាបស និងកាបក្បាលធំមិនមានជម្ងឺនេះទេ ។ ត្រីកាបស៊ីស្មៅប្រវែងតិចជាង ៥ ស.ម ច្រើនប្រទះជម្ងឺសក្បាល ប្រមាត់ស ប៉ុន្តែត្រីកាបស៊ីស្មៅដែលប្រវែងធំជាង ៥ ស.ម មិនមានជម្ងឺនេះទេ។ ភាពទប់ទល់នឹងជម្ងឺរបស់ត្រីអាស្រ័យទៅតាមប្រភេទត្រី ចរឹករស់នៅ និងស៊ីចំណី ស្ថានភាពសុខភាពរបស់ត្រី ។

ដូច្នេះដើម្បីយល់ឱ្យច្បាស់ពីជម្ងឺត្រីត្រូវស្វែងយល់ពីកត្តាខាងក្រៅ និងខាងក្នុងខ្លួនត្រីអោយបានច្បាស់ទើបរកឃើញមូលហេតុដែលបង្កជម្ងឺដល់ត្រី ។

# ជម្ងឺអុជស ឬ ជម្ងឺសកន្ទុយ

ជម្ងឺនេះកើតមាននៅលើត្រីកាបស កាបក្បាលធំ កាបស៊ីស្មៅ និងកាបសាមញ្ញ ។ ជម្ងឺនេះបង្កគ្រោះថ្នាក់យ៉ាងខ្លាំងដល់កូនត្រីពូជ និងត្រីសាច់ ។ ជម្ងឺនេះក៏អាចបង្កឡើងលើកូនត្រីប្រាចិញ្ចឹក្នុងបែរដែរ ហើយគេត្រូវតែដួសវាចេញ ។

I - **មេរោគបង្កជម្ងឺ**

មេរោគបង្កជម្ងឺគឺ Pedomonas dermoalba មានទំហំ 0,៨ - 0,៤ អូម ។

II- **លក្ខណៈនៃជម្ងឺ**

ត្រីស៊ីចំណីតិចរួចលែងស៊ីចំណី នៅក្រោមព្រុយខ្នងជិតមកដល់កន្ទុយមានលេចចេញអុតពណ៌សរួចរាលដាលរហូតមកដល់កន្ទុយ ។ ត្រីមានជម្ងឺហែលយឺតយ៉ាវ កន្ទុយត្រីរឹងរហូតដល់ខ្លួន ពេលខ្លះកន្ទុយត្រីរហែកដាច់ ត្រីនៅស្ងៀមពុំមានលទ្ធភាពធ្វើសកម្មភាព វាអណ្តែតស្ងៀមលើទឹក បន្ទាប់មកដាំក្បាលចុះទៅបាតស្រះងាប់ ។

ចំពោះត្រីអត់ស្រកា ត្រីប្រា សង្កេតឃើញមានសសៃឈាមនៅលើស្បែក ។ ជម្ងឺអុជស ឬ សកន្ទុយច្រើនកើតឡើងក្រោយពីពេលដែលកៀរប្រមូលចាប់កូនត្រី និង ត្រីសាច់ ហើយពេលខ្លះក៏កើតឡើងដោយខ្លួនឯងដែរ ។

III-**វិធីបង្ការ និងព្យាបាលជម្ងឺ**

**១-វិធីបង្ការរោគ** មិនត្រូវកៀរចាប់ត្រីនៅពេលថ្ងៃក្តៅខ្លាំង ពេលសីតុណ្ហភាពទឹកឡើងខ្ពស់ ។ យើងត្រូវកៀរចាប់ត្រីនៅពេលព្រឹកប្រលឹម ឬ នៅថ្ងៃណាដែលមេឃត្រជាក់ ពេលចាប់ត្រីមិនត្រូវធ្វើអោយត្រីមានរបួស ឬ រលាត់ដែលជាមូលហេតុនាំអោយត្រីមានជម្ងឺ ។ មុនពេលលែងត្រីចូលស្រះវិញគម្បីត្រាំត្រីក្នុងទឹកថ្នាំBiomycin ឬ Streptomycin កំហាប់ ១២,៥ ppm ក្នុងរយះពេល ៣0 នាទី ដើម្បីបង្កាជម្ងឺអុជស ។ គេអាចប្រើថ្នាំ CuSo4/ កំហាប់ 0,៥ PPm ដាក់ត្រាំក្នុងស្រះ ។

**២-វិធីព្យាបាល** តាមឯកសាររបស់ប្រទេសចិន គេអាចព្យាបាលជម្ងឺនេះដោយត្រាំត្រីឃឺក្នុងល្បាយទឹកថ្នាំ

- No3Hg ឬ CH3-ជៀសវាង កំហាប់ ២ ppm ត្រាំត្រីក្នុងរយះពេល ២-២,៣0ម៉ោង
- Ca( Ocl )$^2$ ម្សៅក្លរីន កំហាប់ ១ ppm

# គោលការណ៍នៃការបង្ការរោគ

ត្រីជាសត្វរស់នៅក្នុងទឹក យើងពិបាកមើលឃើញសកម្មភាពរបស់វាក្នុងការហែល និងស្វែងរកចំណី ហើយរឹតតែពិបាកក្នុងការពិនិត្យជម្ងឺ និងព្យាបាលជម្ងឺ ។ សត្វគោក្របីជ្រូកមាន់ទាពេលមានជម្ងឺអាចព្យាបាលបាន ដោយបញ្ចូកថ្នាំចូលមាត់ ឬ ចាក់ថ្នាំជាដើម ចំណែកត្រីចិញ្ចឹមក្នុងស្រះការព្យាបាលដោយប្រើថ្នាំមានការលំបាកយ៉ាងខ្លាំង ។

ដូច្នេះការបង្ការរោគចំពោះត្រីមានអត្ថន័យ៉ាងសំខាន់ក្នុងការចិញ្ចឹមត្រី ។ វិធីបង្ការរោគត្រីមានដូចខាងក្រោម

**I-ការរៀបចំស្រះ** ការរៀបចំស្រះក្នុងគោលបំណងពីរគឺ

. ធ្វើអោយស្រះស្អាតគ្មានមេរោគ និងគ្មានជាតិពុលមានគុណភាពទឹកល្អ

. ធ្វើអោយស្រះសំបូរចំណីធម្មជាតិសំរាប់ត្រី

ការរៀបចំស្រះបានល្អមានសារៈសំខាន់ ក្នុងការបង្ការរោគ និងលើកកំពស់ទិន្នផលត្រីចិញ្ចឹម ។

❖ ការរៀបចំស្រះត្រឹមត្រូវតាមបច្ចេកទេសមានផលប្រយោជន៍គឺ:

**១-បន្ថយនូវជម្ងឺត្រី** បំបាត់នូវជាតិពុលមេរោគ និងភ្នាក់ងារចម្លងជម្ងឺនៅក្នុងស្រះអាចបន្ថយនូវជម្ងឺដល់ត្រីក្នុងស្រះ ។

**២-ធ្វើអោយស្រះដែលខ្សត់ចំណីក្លាយជាសំបូរចំណី**

ក្រោយពេលបង្ហូរទឹកចេញ បាចកំបោរ ហាលស្រះ និងដាក់ជីក្នុងស្រះដែលក្សត់ចំណីក្លាយជាសំបូរចំណីធម្មជាតិ ។

**៣-បង្កើនដង់ស៊ីតេត្រីដាក់ចិញ្ចឹម**

ក្រោយពេលរៀបចំស្រះរួចទឹកស្រះមានគុណភាពល្អអាចបង្កើនដង់ស៊ីតេដាក់ចិញ្ចឹមបានច្រើនជាងស្រះដែលពុំបានរៀបចំ ។

❖ ប្រភេទថ្នាំប្រើសំរាប់សំអាតស្រះ

**១ -កំបោរស** ( $CaCo_3$ )

**ក- សំអាតស្រះដែលគោកទឹក**

ក្រោយពេលដែលបង្ហូរទឹកចេញអស់ពីស្រះហើយ រៀបចំបាចកំបោរគ្រប់កន្លែងនៅក្នុងស្រះ ។ បរិមាណកំបោរដែលប្រើគឺ ៧៥០-១០០០ គីឡូក្រាម ១ ហិចតាស្រះ ។

**ខ- សំអាតស្រះដែលមានទឹក**

ស្រះខ្លះមានការលំបាកក្នុងការបង្ហូរទឹកចេញ និងបញ្ចូលទឹកគេធ្វើការសំអាតស្រះដោយប្រើប្រាស់កំបោរ ដូចតទៅ : ស្រះ១ហិចតា ជំរៅទឹកមធ្យម ១ម ប្រើកំបោរ ១៩០០-២៣០០គីឡូក្រាម ប្រើទូកចែវបាចគ្រប់ កន្លែងក្នុងស្រះក្រោយ ១ថ្ងៃ កាយត្រឡប់ភក់បាតស្រះ ដើម្បីអោយកំបោរជ្រាបចូលសព្វល្អ ។

**គ- លទ្ធផលនៃការសំអាតស្រះ ដោយប្រើកំបោរស**

កំបោរសអាចសំលាប់ពពួកសត្វល្អិត ត្រីកាចដែលមានគ្រោះថ្នាក់ដល់ត្រីចិញ្ចឹម ។ ពពួកសត្វស្រទាប់បាតក៏ត្រូវស្លាប់ដែរ ដូចជា ខ្យង ក្តាម និងសត្វខ្លួនទន់មួយចំនួនពពួកមីក្រុបប៉ារ៉ាស៊ីតមួយចំនួនក៏ត្រូវស្លាប់ក្រោមឥទ្ធិពលនៃកំបោរសដែរ ។

- កំបោរសជួយជំរុញសមីការបំបែកសារធាតុសរីរាង្គក្នុងស្រះ
- កំបោរស ជួយបង្កើន និងរក្សាលំនឹង $P^H$ សមស្របសំរាប់ត្រី
- កំបោរសមាន Ca ដែលជាសមាសធាតុចាំបាច់សំរាប់ចិញ្ចឹមជិវិតពពួកប្លង់តុងសត្វរុក្ខជាតិដែលជាចំណីត្រី

**២-ថ្នាំម្សៅសសំលាប់មេរោគ**

ជាធម្មតាម្សៅសសំលាប់មេរោគមានសារធាតុ Clក្លូ ប្រហែល ៣០ ភាគរយ ។ ក្រោយពេលបាចក្នុងទឹកវាមានសមីការ

$$CaOCl_2 + H_2O \longrightarrow HclO + Ca\begin{matrix} O \\ OH \end{matrix}$$

បន្ទាប់មក HclO មានប្រតិកម្មរំដោះ $O_2$ ចេញ ពេលនោះឥទ្ធិពលសំលាប់មេរោគយ៉ាងខ្លាំង ។

**ក-របៀបប្រើ** ប្រើម្សៅសនេះសំអាតស្រះជាមួយកំហាប់ ២0 ppm យកថ្នាំម្សៅនេះលាយជាមួយទឹកក្នុងធុង ឬ ចានកាធុនអំពីជ័ររួចយកទៅបាចក្នុងទឹកស្រះ ។

**ខ- លទ្ធផលនៃការសំអាតស្រះ** លទ្ធផលនៃការប្រើថ្នាំម្សៅសសំលាប់មេរោគនេះដូចគ្នានឹងការប្រើកំបោរសដែរ នៅកន្លែងខ្លះដែលពុំអាចប្រើកំបោរសបាន ឬ ត្រូវការប្រញាប់ប្រើក្នុងស្រះត្រីគេអាចប្រើម្សៅសនេះជំនួស ប៉ុន្តែតំលៃវាខ្ពស់ជាងកំបោរស ។

៣-Rotenone: ជាសារធាតុពណ៌លឿងរលាយក្នុងល្បាយសរីរាង្គ ។ចំរាញ់ចេញពីឫសរុក្ខជាតិអំបូរសណ្តែកពីរប្រភេទ ។ Rotenone មានឥទ្ធិពលសំលាប់ត្រីកាចក្នុងស្រះ និងសត្វល្អិត ។

៤- DDT ( Dichloro diphenyl – trichlororolthane ) មានឥទ្ធិពលសំលាប់មេរោគសត្វល្អិតយ៉ាងខ្លាំងពីរមុនគេនិយមប្រើប្រាស់ប៉ុន្តែបច្ចុប្បន្ននេះប្រទេសជាច្រើនបានហាមប្រើប្រាស់ ព្រោះសារធាតុនេះមានឥទ្ធិពលខ្លាំងអាចបណ្តាលអោយងាប់ត្រី ឬមានគ្រោះថ្នាក់ដល់អ្នកដែលចុះក្នុងស្រះ ។

II - **ការគ្រប់គ្រងថែទាំស្រះចិញ្ចឹមត្រី**

ក្នុងរយះពេលចិញ្ចឹមត្រីការងារគ្រប់គ្រងស្រះចិញ្ចឹមត្រី មានឥទ្ធិពល និងទំនាក់ទំនងដល់ការកើតជម្ងឺត្រីប្រសិនបើគ្រប់គ្រងបានល្អ ត្រីគ្មានជម្ងឺមានការធំធាត់ល្អ ផ្ទុយទៅវិញបើគ្រប់គ្រងមិនល្អ និងបណ្តាលអោយត្រីឈឺ ។

- ក្នុងការគ្រប់គ្រងថែទាំស្រះចិញ្ចឹមត្រី ត្រូវយកចិត្តទុកដាក់ចំណុចដូចខាងក្រោម:

**១-ត្រួតពិនិត្យស្រះ** ដើរពិនិត្យមើលស្រះជារៀងរាល់ថ្ងៃ ក្នុងមួយថ្ងៃចំនួន ៣ ដង គឺពេលព្រឹកព្រលឹម ពេលម៉ោង ២-៣រសៀល ឬ ពេលថ្ងៃល្ងាចអស្តង្គត។ ក្នុងពេលដើរពិនិត្យត្រូវពិនិត្យមើលសភាពត្រីស៊ីចំណី ត្រីហើបក្បាល និងពិនិត្យស៊ីតុណ្ហភាពទឹក អុកស៊ីសែនរលាយក្នុងទឹក $P^H$ ទឹក ។

**ន**-ត្រីងើបក្បាលនៅពេលព្រឹក ហើយឆាប់លិចទៅវិញគឺមានកំរិតខ្វះ $O^2$ ស្រាល បើត្រីងើបក្បាលនៅពេលយប់គឺកំរិតធ្ងន់ ។

**២-ការអោយចំណី និងបាចជីក្នុងស្រះ**

**ក -ការអោយចំណី** គុណភាពចំណីមានសារៈសំខាន់ចំពោះត្រីចិញ្ចឹម ចំណីត្រូវសំបូរសារធាតុចិញ្ចឹមសមស្របសំរាប់ត្រីទៅតាមប្រភេទ និងអាយុរបស់ត្រី ។ ជាធម្មតាគេអោយចំណីត្រី ២ ដងនៅពេលព្រឹក និងពេលល្ងាចថ្ងៃរសៀល

**ខ-ការបាចជី** ការបាចជី គឺជាការបង្កើនសារធាតុចិញ្ចឹមក្នុងស្រះ ធ្វើអោយបួង់តុងសត្វរុក្ខជាតិលូតលាស់ល្អ ជាចំណីត្រី ។ ការបាចជីចែកជា ២ ដំណាក់កាល គឺការបាចជីពេលរៀបចំស្រះ និងការបាចជីពេលដាក់ត្រីចិញ្ចឹមហើយ ។

ឧ- ការបាចជីលាមកគោ ពេលរៀបចំស្រះ គឺ ២,២៥- ៣,៧៥ T/ ha

**៣-បំបាត់ចោលកំទិចកំទីរុក្ខជាតិ និងសត្រូវរបស់ត្រីពីក្នុងស្រះ**

ត្រូវរើសកំទេចកំទីសៅ ចក ដែលមានក្នុងស្រះចេញព្រោះវាដណ្តើម $O_2$ ពីក្នុងទឹក ។ ពពួកសត្វខ្យង កូនកង្កែប ក្តាម ត្រូវកំចាត់ចោលព្រោះវាដណើមចំណីរបស់ត្រី ។ កំទេចកំទីសំរាមវាចំលងមេរោគដល់ត្រីក៏ត្រូវដកចេញពីស្រះដែរ ។

**៤-ការបញ្ចេញបញ្ចូលទឹកក្នុងស្រះ** ជាធម្មតាក្នុងរយៈពេលកន្លះខែម្តង ត្រូវបញ្ចូលទឹកថ្មីទៅក្នុងស្រះបន្ថែមពី ១០-២០ស.ម ។ ក្នុងពេលដែលស្រះសំបូរសារធាតុចិញ្ចឹមពេក ឬ ពេលមានត្រីហើបក្បាលត្រូវបញ្ចេញទឹកចោលរួច បញ្ចូលទឹកថ្មីមកជំនួសវិញ ។

**៥- ការការពារមិនអោយមេរោគចូលក្នុងស្រះបង្កជម្ងឺដល់ត្រី**

- ត្រូវធ្វើអនាម័យស្រះ ប្រភពទឹកបញ្ចូលស្រះ អនាម័យចំណី និងសំភារះប្រើប្រាស់ដើម្បីការពារមិនអោយមានមេរោគចូលទៅក្នុងស្រះចិញ្ចឹមត្រី ។

- ត្រូវជ្រើសរើសពូជត្រីដាក់ចិញ្ចឹមដែលជាពូជត្រីល្អមានសុខភាពល្អជាត្រីគ្មានជម្ងឺគ្មានមេរោគជាប់ជាមួយ ។

# គោលការនៃរោគវិនិច្ឆ័យ

ដើម្បីព្យាបាលជំងឺត្រីអោយមានប្រសិទ្ធភាព ជាដំបូងយើងត្រូវធ្វើរោគវិនិច្ឆ័យជម្ងឺត្រីអោយបានច្បាស់លាស់ ទើបផ្តល់ថ្នាំព្យាបាលត្រូវនឹងជម្ងឺ ។

**វិធីសាស្រ្តនៃរោគវិនិច្ឆ័យរួមមាន**

I- **ត្រួតពិនិត្យរោគនៅនឹងកន្លែង**

**១-ស្វែងយល់អំពីស្រះត្រីឈឺ** ពិនិត្យមើលស្ថានភាពហ្វូងត្រី សភាពត្រីហែល ត្រីហើបក្បាល ត្រីងាប់ ។ ពិនិត្យមើលស្ថានភាពស្រះ គុណភាពទឹក និងមជ្ឈដ្ឋានជុំវិញ ដូចជាការប្រើថ្នាំសំលាប់សត្វល្អិតលើដំណាំស្រូវ ឬការបង្ហូរកាកសំណល់ជាតិគីមីពីរោងចក្រនៅជិតស្រះចិញ្ចឹមត្រី ។

**២-ស្វែងយល់អំពីការគ្រប់គ្រងក្នុងការចិញ្ចឹមត្រី** ការគ្រប់គ្រងស្រះពុំបានល្អដូចជាបាចជីច្រើនហួស ការអោយចំណីខ្វះជីជាតិ ឬអោយចំណីច្រើនពេកបណ្តាលអោយត្រីស៊ីសល់ ស្អុយទឹក ធ្វើអោយមានមេរោគក្នុងទឹក ។

ការចាប់ត្រីដោយកៀរអួន ធ្វើអោយរលាត់របួសត្រី ការកំចាត់ចោលមិនអស់នូវត្រីកាច ខ្យង កុក សត្វស្លាប ដែលជាភ្នាក់ងារចម្លងជម្ងឺដល់ត្រី ។

II- **ត្រួតពិនិត្យមើលខ្លួនត្រីឈឺ**

**១-ត្រួតពិនិត្យដោយភ្នែកទទេ**

- **ក-** ពិនិត្យមើលខ្លួនត្រី ទ្រង់ទ្រាយខាងក្រៅរបស់ត្រី
- **ខ-** ពិនិត្យមើលស្រកីត្រី
- **គ-** ពិនិត្យមើលគ្រឿងក្នុងត្រី ពិសេសពោះវៀនត្រី

**២-ត្រួតពិនិត្យមើលមេរោគ ដោយកែវពង្រីក ឬ អតិសុខុមទស្សន៍**

ដើម្បីធ្វើរោគវិនិច្ឆ័យអោយកាន់តែច្បាស់លាស់ ត្រួតពិនិត្យមើលថែមទៀតដោយកែវពង្រីក ឬ មើលដោយអតិសុខុមទស្សន៍ ។